# សេចក្ដីសម្រេចលើសំណុំរឿង ឱសថរត់ពន្ធ(ហ្វីលីពីន)[1]

**(<u>សេចក្តីសម្រេចលេខ ១២៤៤៦១ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០០</u>)**

នៅក្នុងសេចក្តីសម្រេច ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៨ តុលាការបាន ច្រានចោលបណ្តឹងទាមទារមួយរបស់ដើមបណ្តឹង ដោយសាលាដំបូង ចេញ សេចក្តីសម្រេចបដិសេធដីកាឆែកឆេរ ដែលបានចេញរួចហើយ និងបញ្ជាឱ្យ សងត្រឡប់មកវិញនូវទំនិញ ដែលបានរឹបអូសនោះ ដោយសំអាងលើហេតុផល ថា ដីកាឆែកឆេរនោះ មិនស្របទៅនឹងរដ្ឋធម្មនុញ្ញ ។

ពេលនេះ ដើមបណ្តឹងបានស្នើសុំឱ្យមានការពិចារណាឡើងវិញ លើ ចំណុចខ្លះ នៃសេចក្តីសម្រេចដែលបានលើកឡើងខាងលើ ដោយបានអះអាងថា ឱសថដែលត្រូវបានរឹបអូសនោះ ជាកម្មវត្ថុនៃដីកា ដែលត្រូវបានចាត់ទុកជា មោឃៈនោះ មិនអាចត្រូវបានបញ្ជូនត្រឡប់ទៅវិញបានឡើយ ដោយសារថា ទំនិញ ទាំងនោះគឺជា ទំនិញរត់ពន្ធ ។

នៅក្នុងញត្តិដែលស្នើសុំការពិចារណាឡើងវិញនោះ ដើមបណ្តឹមបាន ភ្ជាប់មកជាមួយនូវឧបសម្ព័ន្ធ ដែលមានបំណងបង្ហាញថា ឱសថចំនួន ៥២ ប្រអប់ ដែលត្រូវបានរឹបអូសដោយដីកា ដែលត្រូវបានចាត់ទុកជាមោឃៈនោះ បើយោងតាមការពិសោធន៍របស់មន្ទីរពិសោធន៍ បានបង្ហាញថា មិនមែនជា

[1] PEOPLE OF PHILLIPINES, Petitioner, VS. JUDGE ESTRELLA T. ESTRADA, Presiding Judge, RTC Br. 83, Quezon City &AIDEN LANUZA, respondents

ឱសថក្លែងក្លាយក៏ពិតមែន ប៉ុន្តែទាំងនោះ ជាឱសថ ដែលត្រូវបាននាំចូលដោយខុសច្បាប់ ។

ទោះបីជាឱសថ ដែលត្រូវបានរឹបអូសទាំងនោះ មិនមែនជាឱសថក្លែងក្លាយក្តី ហើយទោះបីជាឱសថទាំងនោះ ត្រូវបានផលិតដោយមានសមាសភាគ និងគ្រឿងផ្សំត្រឹមត្រូវ ក៏ដោយ ប្រសិនបើអ្នកផលិត ឬអ្នកលក់ មិនទទួលបានអាជ្ញាបណ្ណ ឬការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋាភិបាលទេ នោះផលិតផលឱសថនោះ មិនអាចត្រូវបានបញ្ជូនត្រឡប់ទៅវិញបានឡើយ ទោះបីជាដីកាឆែកឆេរ មិនបានបង្ហាញថា មានភាពខុសច្បាប់ក្តី ។ ករណីនេះ ជាបន្ទុករបស់ភាគី ដើម្បីឱ្យចៅក្រមសាលាដំបូងអាចជឿជាក់បាន អំពីភវនីយហេតុ (probable cause) ដែលកើតឡើង និងដើម្បីឱ្យភស្តុតាងដាក់ជូនតុលាការបង្ហាញថា ភាគីដែលដីកាបានចង្អុលបង្ហាញនោះ មិនបានទទួលការអនុញ្ញាតត្រឹមត្រូវពីការិយាល័យចំណីអាហារ និងឱសថ (Bureau of Foods and Drugs-BFAD) ត្រូវបានទទួលស្គាល់ ។

ប្រសិនបើមានទឡ្ហីករណ៍បញ្ជាក់ថា ការកាន់កាប់ទំនិញ ឬវត្ថុដែលបានរឹបអូសនោះ មានភាពខុសច្បាប់ ឬខ្វះការអនុញ្ញាតត្រឹមត្រូវពីស្ថាប័នមានសមត្ថកិច្ច នោះភាគីដែលទាមទារឱ្យប្រគល់ទំនិញត្រឡប់ទៅវិញ ត្រូវបង្ហាញនូវអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច លើការផលិត ការលក់ ឬការកាន់កាប់ឱសថនោះ ដើម្បីជាការឆ្លើយតបចំពោះទឡ្ហីករណ៍ខាងលើ ។ ភាពមិនក្លែងក្លាយនៃផលិតផលឱសថ មិនមែនជាយុត្តិកម្មគ្រប់គ្រាន់សម្រាប់ការប្រគល់ត្រឡប់ទៅវិញ នៃឱសថដែលបានរឹបអូសឡើយ ។ ករណីនេះ ត្រូវតែបញ្ជាក់អំពីការអនុលោមតាមលក្ខខណ្ឌ កំណត់ដោយច្បាប់ស្តីពីលិខិតអនុញ្ញាត និងអាជ្ញាបណ្ណ ។

ចំណេះដឹងអំពីផលិតកម្ម នៃឱសថ អាចទទួលបាន និងចែកចាយដោយងាយ ប៉ុន្តែចំណេះដឹងនេះ មិនមែនត្រូវបានចែកចាយដល់សាធារណជនធម្មតាឡើយ ហើយពួកគាត់ពឹងផ្អែកតែទៅលើវេជ្ជបញ្ជាប៉ុណ្ណោះ ។ ផ្ទុយទៅវិញ ចំណេះដឹងនេះ ត្រូវបានចែកចាយដល់ឃ្លាំងឱសថឯនោះទេ ។ ជាការពិតណាស់ ដែលថា មានតែអ្នកដែលមានឱកាសិក្សាលម្អិតទៅលើការរៀបចំ សមាសភាគ និងលក្ខណៈរូបនៃឱសថទាំងនេះ នៅក្នុងវិស័យទូទៅផ្នែកវេជ្ជសាស្ត្រ ឱសថសាស្ត្រ នីតិគីមីវិទ្យា (forensic chemistry) ដែលមានចំណេះដឹងច្បាស់លាស់អំពីឥទ្ធិពល នៃឱសថ និងអំពីសមាភាគនៃឱសថនោះ[2] ។ មនុស្សទូទៅ មិនអាចពិនិត្យពិច័យសមាសភាគគីមី នៃឱសថដែលពួកគេប្រើប្រាស់ឡើយ ប៉ុន្តែពួកគេផ្អែកតែលើឈ្មោះថ្នាំ ទោះបីជាឱសថនោះមានយីហោល្បីឈ្មោះ ឬជាឱសថទូទៅក្តី ហើយពួកគាត់គ្រាន់តែពិនិត្យមើលថា តើថ្នាំនោះត្រូវជាមួយនឹងវេជ្ជបញ្ជា ដែលចេញដោយវេជ្ជបណ្ឌិតដែរឬយ៉ាងណា ប៉ុណ្ណោះ ។

ការពិសោធន៍របស់មន្ទីរពិសោធន៍ នៅតែមានភាពចាំបាច់សម្រាប់ការកំណត់អំពីភាពមិនក្លែងក្លាយ នៃឱសថ ។ គុណភាពព្យាបាលនៃផលិតផលឱសថ មិនមែនជាភស្តុតាង បង្ហាញពីសុវត្ថិភាពពេញលេញ សម្រាប់អ្នកប្រើប្រាស់ចុងក្រោយ (End-user) ដែលគ្រាន់តែសន្មត់អំពីផលប្រយោជន៍ នៃផលិតផលនោះឡើយ ។ ដោយផ្អែកលើកាតព្វកិច្ចរបស់រដ្ឋ ក្នុងការការពារ និងលើកកម្ពស់សិទ្ធិទទួលបានសុខភាពរបស់ប្រជាពលរដ្ឋ និងការផ្សព្វផ្សាយចំណេះអំពីសុខភាពដល់ពួកគេ[3] ដើម្បីអភិវឌ្ឍសុខុមាលភាព និងការយល់ដឹង[4] កិច្ចការនេះ ត្រូវស្ថិតក្នុង

---

[2] See People vs. Angeles, 209 SCRA 799 [1992].

[3] Article II, Section 15, 1987 Constitution

[4] Article XIV, Section 19(1)

សមត្ថកិច្ចរបស់រដ្ឋាភិបាល ក្នុងការចាត់ចែង និងគ្រប់គ្រងកំណើនឱសថនៅក្នុងទីផ្សារ ។

រដ្ឋធម្មនុញ្ញបានកំណត់ថា "រដ្ឋ ត្រូវដាក់ចេញនូវយុទ្ធសាស្ត្រដែលមានលក្ខណៈសមាហរណកម្ម និងគ្រប់ជ្រុងជ្រោយ សម្រាប់ការអភិវឌ្ឍវិស័យសុខាភិបាល ដោយជម្រុញដល់ការផលិតទំនិញ សេវាសុខាភិបាល និងសង្គមចាំបាច់ដទៃទៀតសម្រាប់ពលរដ្ឋ ក្នុងតម្លៃសមរម្យ[5]"។ នេះជាហេតុផលដែលរដ្ឋ ត្រូវបង្កើត និង ធានានូវប្រព័ន្ធនិយ័តភាពអាហារ និងឱសថប្រកបដោយប្រសិទ្ធភាព[6] ។ BFAD គឺជាភ្នាក់ងាររដ្ឋាភិបាល ដែលបង្កើតឡើងដោយច្បាប់ ដើម្បីបង្កើតសេចក្តីសម្រេចផ្តល់អាណត្តិ និងការអនុញ្ញាត លើការផលិតឱសថ ព្រោះវាពាក់ព័ន្ធនឹងជំនាញខាងបច្ចេកទេស ដែលស្ថិតក្នុងសមត្ថកិច្ចពិសេស ។ សុខភាពរបស់ប្រជាពលរដ្ឋ ត្រូវតែទទួលបានការយកចិត្តទុកដាក់ខ្ពស់ ។ ចំពោះប្រជាពលរដ្ឋទូទៅ ឱសថគឺជាមធ្យោបាយដែលធ្វើឱ្យពួកគេទទួលបានសុខភាពល្អឡើងវិញ ។

ប្រសិនបើឱសថចំនួន ៥២ កញ្ចប់ ដែលបានរឹបអូសនោះ មានភាពត្រឹមត្រូវតាមបែបឱសថសាស្ត្រ ប៉ុន្តែមិនមានឯកសារត្រឹមត្រូវ គឺគេត្រូវតែកំទេចចោលភ្លាមៗ តាមការកំណត់របស់ច្បាប់ ដើម្បីធានាកុំឱ្យមានការប្រើប្រាស់ឱសថដោយលួចលាក់ ។

ចុងចម្លើយ មិនអាចផ្អែកលើសេចក្តីថ្លែងការណ៍ របស់សាលាដំបូង (trial court) ថាដើមបណ្តឹង "មិនអាចចោទដោយគ្មានភស្តុតាងបានឡើយ នៅក្នុងបណ្តឹង ដោយសារថា នៅក្នុងពាក្យស្នើសុំដីកាឆែកឆេរនោះគឺចោទប្រកាន់ថា ឱសថនោះជាផលិតផលក្លែងក្លាយ មិនមានយីហោ (misbranded) ខូចគុណ

[5] Article XIII, Section 11.

[6] Article XIII, Section 12.

ភាព ឬមិនបានចុះបញ្ជី” [7] ដើម្បីទទួលបានការប្រគល់ត្រឡប់នូវឱសថនោះឡើយ ។ គោលប្រតិបត្តិនៃច្បាប់ (Policy of law) ដែលបានកំណត់នៅក្នុង R.A. No. 8203 គឺដើម្បីការពារអ្នកប្រើប្រាស់ ក៏ដូចជាពាណិជ្ជករដែលមានអាជ្ញាបណ្ណ ។ រឿងសំខាន់នៅក្នុងការការពារអ្នកប្រើប្រាស់នេះគឺ រដ្ឋាភិបាលខ្លួនឯង ដែលជាអ្នកផ្គត់ផ្គង់ និងចែកចាយឱសថទៅសហគមន៍មូលដ្ឋាន តាមរយៈការផ្តល់ជាជំនួយដោយផ្ទាល់ទៅមណ្ឌលសុខភាពនៅតាមមូលដ្ឋាន ឬតាមរយៈកម្មវិធីសប្បុរសធម៌ក្រៅរដ្ឋាភិបាលផ្សេងៗ ។ មានតែឱសថដែលទទួលបានការអនុញ្ញាតត្រឹមត្រូវពីរដ្ឋាភិបាលប៉ុណ្ណោះ ដែលអាចចរាចរនៅក្នុងទីផ្សារបាន ។ យើងមិនត្រូវបណ្តែតបណ្តោយឱ្យប្រជាពលរដ្ឋរងគ្រោះនោះទេ ព្រោះថា អាយុជីវិត និងសុខភាពរបស់ប្រជាពលរដ្ឋ មានតម្លៃដូចជាអត្ថិភាពនៃរដ្ឋអញ្ចឹងដែរ ។

ហេតុដូច្នេះហើយ យើងសម្រេចទទួលយកញត្តិស្នើសុំឱ្យពិចារណាឡើងវិញនេះ ។ បន្ថែមលើនេះ មន្ត្រីច្បាប់ (solicitor general) ត្រូវជូនដំណឹងទៅBFAD ក្នុងរយៈពេល ៥ ថ្ងៃ បន្ទាប់ពីទទួលបានសេចក្តីសម្រេចនេះ ដើម្បីឱ្យ BFAD កំទេចឱសថដែលត្រូវរឹបអូសទាំង ៥២ ប្រអប់ក្នុងរយៈពេល៥ថ្ងៃ បន្ទាប់ពីទទួលបានដំណឹង ។ មន្ត្រីច្បាប់ ត្រូវរាយការណ៍ជូនតុលាការ អំពីបញ្ហានេះ ក្នុងរយៈពេល ៥ ថ្ងៃបន្ទាប់ពីការកំទេចចោលឱសថនោះ ។

សម្រេចដោយ ៖ Melo, (Chairman), Puno, និង Mendoza, JJ.

For English version: https://sherloc.unodc.org/cld/case-law-doc/

[7] Comment on Partial Motion for Reconsideration, p. 3; Rollo, p. 280; Order of RTC Dated December 7, 1995.